BMI0117

# សម្ភាសន៍ជាមួយឈ្មោះ ចាន់ រតនា ភេទប្រុស អាយុ៥៨ឆ្នាំ

## មុខងារខ្មែរក្រហមៈ ទាហាន

## ស្រុកកំណើតនៅភូមិបឹង ឃុំរអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ

## សព្វថ្ងៃរស់នៅភូមិបន្ទាយឆ្មារខាងលិច ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ឡុង ដានី

០១:១១:៣៦

២៨ទំព័រ

ដានី ៖ លោកពូ!ខ្ញុំចង់ស្គាល់ឈ្មោះលោកពូ លោកពូឈ្មោះអីដែរ?

រតនា ៖ ឈ្មោះ ចាន់ រតនា ។

ដានី ៖ លោកពូសព្វថ្ងៃអាយុប៉ុន្មានហើយ?

រតនា ៖ អាយុ៥៨ឆ្នាំ ។

ដានី ៖ លោកពូឈ្មោះ ចាន់ រតនា លោកពូអត់មានឈ្មោះអីផ្សេងទៀតទេ?

រតនា ៖ អត់ទេ!

ដានី ៖ បាទ!លោកពូស្រុកកំណើតលោកពូនៅណាដែរ?

រតនា ៖ នៅឯព្រះវិហារ ។

ដានី ៖ ភូមិអី ឃុំអីដែរនៅព្រះវិហារ?

រតនា ៖ នៅភូមិបឹង ឃុំរអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ។

ដានី ៖ សព្វថ្ងៃលោកពូរស់នៅភូមិអីដែរ?

រតនា ៖ សព្វថ្ងៃនៅភូមិបន្ទាយឆ្មារខាងលិច ។

ដានី ៖ ឃុំ?

រតនា ៖ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

ដានី ៖ បាទ!ប្រពន្ធលោកពូគាត់ឈ្មោះអីដែរ?

រតនា ៖ សាំង ហួយ ។

ដានី ៖ សព្វថ្ងៃគាត់អាយុប៉ុន្មានដែរ?

រតនា ៖ អាយុ៤០ឆ្នាំ ។

ដានី ៖ គាត់អ្នកស្រុកភូមិនៅហ្នឹងដែរឬក៏មកពីណា?

រតនា ៖ គាត់អ្នកសៀមរាប ។

ដានី ៖ ស្រុកកំណើតគាត់នៅសៀមរាប?

រតនា ៖ បាទ!

ដានី ៖ នៅណាដែរ នៅសៀមរាប?

រតនា ៖ នៅខាងសស្តំ ភូមិសស្តំ ឃុំសស្តំ ហ្នឹងឯង ។

ដានី ៖ ស្រុកអីគេ?

រតនា ៖ ស្រុកពួក ខេត្តសៀមរាប ។

ដានី ៖ បាទ!ពូមានកូនចៅ ប៉ុន្មាននាក់ដែរ?

រតនា ៖ កូនចៅ ៦នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

រតនា ៖ ស្រី៣នាក់ ប្រុស៣នាក់ ។

ដានី ៖ បាទ!សព្វថ្ងៃពូប្រកបរបរធ្វើអីដែរ?

រតនា ៖ ធ្វើស្រែ ។

ដានី ៖ មានធ្វើចំការដែរ?

រតនា ៖ ចំការធ្វើអត់កើតទេ ឈប់ធ្វើ ។

ដានី ៖ ពូធ្វើតែស្រែទេ អត់មានធ្វើអីទៀតទេ?

រតនា ៖ បាទ!ធ្វើតែស្រែ ។

ដានី ៖ ឪពុកពូគាត់ឈ្មោះអីទៅ?

រតនា ៖ ឪពុកខ្ញុំគាត់ឈ្មោះជាតិ ។

ដានី ៖ អីជាតិ?

រតនា ៖ មាន ។

ដានី ៖ មាន ជាតិ?

រតនា ៖ បាទ!

ដានី ៖ សព្វថ្ងៃគាត់នៅរស់ទេ ឬក៏ស្លាប់អស់ហើយ?

រតនា ៖ ស្លាប់អស់ហើយ ។

ដានី ៖ គាត់ស្លាប់តាំងពីអន្កាល់?

រតនា ៖ ស្លាប់តាំងពីឆ្នាំ៧០ ។

ដានី ៖ គាត់ស្លាប់ដោយសារមូលហេតុអីដែរ?

រតនា ៖ គាត់ត្រូវអំពើគេម៉េចទេ កាលពីដើមគេថាត្រូវអំពើគេ ។

ដានី ៖ បាទ!ចុះម្តាយពូ?

រតនា ៖ ម្តាយឈ្មោះ ឡាត ។

ដានី ៖ អី ឡាត?

រតនា ៖ ដុះ ឡាត ។

ដានី ៖ គាត់សព្វថ្ងៃ?

រតនា ៖ ស្លាប់ ។

ដានី ៖ គាត់ស្លាប់តាំងពីអន្កាល់?

រតនា ៖ ស្លាប់ឆ្នាំ៧៣ ។

ដានី ៖ គាត់ស្លាប់ដោយសារអីដែរ?

រតនា ៖ ស្លាប់នឹងជំងឺ គេហៅជំងឺរាកឈាម ។

ដានី ៖ បាទ!ពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

រតនា ៖ បងប្អូន៣នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន៣នាក់?

រតនា ៖ ស្រី១ ប្រុស២ ។

ដានី ៖ បាទ!ពូកូនទីប៉ុន្មាន?

រតនា ៖ ខ្ញុំកូនទី៣ ។

ដានី ៖ ពៅគេអញ្ចឹង?

រតនា ៖ ពៅគេ ។

ដានី ៖ កាលពីក្មេងៗមានបានរៀនសូត្រអីដែរឬអត់?

រតនា ៖ រៀន ។

ដានី ៖ រៀនដល់ណា?

រតនា ៖ រៀនដល់ថ្នាក់ទី៩ ។

ដានី ៖ ថ្នាក់ទី៩?

រតនា ៖ បាទ!

ដានី ៖ រៀននៅសាលាណា?

វតនា ៖ សាលានៅក្នុងភូមិ សាលានៅស្រុកនោះ ។

ដានី ៖ ពូឈប់រៀននៅឆ្នាំណា?

វតនា ៖ ឈប់ពីឆ្នាំ៧០ហ្នឹងហើយ ធ្វើទាហានឈប់ ។

ដានី ៖ មូលហេតុអីបានឈប់?

វតនា ៖ ដល់រដ្ឋប្រហារគេម៉ោ អាប៉ុស្តិ៍ខ្មែរក្រហមហ្នឹងគេបញ្ចុះបញ្ចូលប្រជុំក្នុងភូមិហ្នឹងថា ត្រូវតែតស៊ូរំដោះប្រទេសជាតិ ដើម្បីជួយស្រោចស្រង់ប្រទេសយើង ឲ្យរួចផុតពីយួនឈ្លានពាន ។

ដានី ៖ បាទ!ដល់ពេលគេបញ្ចុះបញ្ចូលអញ្ចឹងពូក៏ចូលដែរ?

វតនា ៖ បាទ!ខ្ញុំក៏ចូល ។

ដានី ៖ ចូលពូចាំខែឆ្នាំពូចូលជាមួយខ្មែរក្រហមទេ?

វតនា ៖ ដូចមិនបានចាំទេ ភ្លេចហើយ ។

ដានី ៖ រដ្ឋប្រហារបានប្រហែលប៉ុន្មាន រយៈពេលប៉ុន្មានបានពូចូល?

វតនា ៖ បានប្រហែលជា២ខែឬ៣ខែហ្នឹង គេផ្សព្វផ្សាយហ្នឹងខ្ញុំក៏ចូល មិនដឹងជាថ្ងៃប៉ុន្មានផងមិនបានកត់ត្រាទុក ដឹងតែឆ្នាំ៧០ប៉ុណ្ណឹងឯង កាលហ្នឹងចូលធ្វើទាហាននឹងគេ ហើយគេក៏បញ្ជូនទៅនៅព្រំដែនលាវនោះ ។

ដានី ៖ ចូលហើយចូលទាហានភ្លាម?

វតនា ៖ បាទ!ចូលហើយ គេឲ្យអាវុធ ឲ្យកាំភ្លើង ។

ដានី ៖ ទៅនៅកន្លែងណា នៅព្រំដែនលាវហ្នឹង?

វតនា ៖ នៅស្រុកកំពង់ស្រឡាវ ។

ដានី ៖ ខេត្តព្រះវិហារដែរ?

វតនា ៖ បាទ!ខេត្តព្រះវិហារ ប៉ុន្តែលាវ ជាប់ទន្លេមេគង្គ ។

ដានី ៖ នៅជាប់ទន្លេមេគង្គ?

វតនា ៖ បាទ!ជិតព្រំដែនលាវ ខ្មែរនឹងលាវ ខ្មែរម៉ាចហៀង លាវម៉ាចហៀង ។

ដានី ៖ ជិតឆែបដែរ?

វតនា ៖ បាទ!ផ្លូវទៅឆែបនឹងហើយ ខ្ញុំឡានតាមផ្លូវនឹងហើយផ្លូវទៅកំពង់ស្រលាវ ផ្លូវឆែប ផ្លូវឡើងទៅព្រះនន្ទ័លអីហ្នឹង ។

ដានី ៖ ពូធ្វើនៅហ្នឹងនៅក្នុងកងពលអីគេដែរ?

រតនា ៖ កងពល!អាហ្នឹងមិនមែនជាកងពលទេ គេហៅភូមិភាគ បាទ!ភូមិភាគពិសេស ។

ដានី ៖ ភូមិភាគពិសេស?

រតនា ៖ បាទ!ភូមិពិសេស ឬមជ្ឈិមបក្សហ្នឹង កន្លែងពួកខ្ញុំនៅសុទ្ធតែ អត់មានអាវខ្មៅទេ ។

ដានី ៖ អត់មានអាវខ្មៅទេ?

រតនា ៖ បាទ!បើម៉ោពេញនេះសុទ្ធតែអាវខ្មៅ តាមខេត្តនានា ខោអាវស្មៀកពាក់សុទ្ធតែខោអាវខៀវ ។

ដានី ៖ បាទ!ខោអាវខៀវ?

រតនា ៖ បាទ!ខោអាវខៀវបើកយកម៉ោពីចិន ។

ដានី ៖ តាំងពីឆ្នាំ៧០ ម៉ោហ្នឹង?

រតនា ៖ បាទ!

ដានី ៖ ពីណាគេប្រធានកាលហ្នឹង?

រតនា ៖ ប្រធានគេសម្លាប់ចោលហើយ ប្រធានភូមិភាគ ។

ដានី ៖ ឈ្មោះអី?

រតនា ៖ ឈ្មោះ ហង់ ។

ដានី ៖ ឈ្មោះតាហង់?

រតនា ៖ បាទ!តាហង់ គាត់ប្រធានភូមិភាគពិសេស ។

ដានី ៖ ប្រធានតំបន់១០៣?

រតនា ៖ បាទ!១០៣ហើយមើល៉ទៅ មិនដឹងប៉ុន្មានទេភ្លេចបាត់ហើយ ។

ដានី ៖ ស្គាល់ឈ្មោះតែហង់រទេ ឈ្មោះគាត់ពេញឈ្មោះអីទៅ?

រតនា ៖ អត់!ស្គាល់តែហង់ៗហ្នឹង ។

ដានី ៖ ហ្នឹងប្រធានរបស់ពូ?

រតនា ៖ បាទ!ហ្នឹងហើយ ។

ដានី ៖ តែកងទ័ពគាត់ក្តាប់?

រតនា ៖ កងទ័ពក៏គាត់ អ្នកណាក៏គាត់ក្តាប់ ក្តាប់ទាំងអស់ ទាំងប្រជាជន ទាំងរាស្រ្តទាំងអស់ ។

ដានី ៖ អញ្ចឹងកន្លែងរបស់ពូហ្នឹងគេហៅកង?

រតនា ៖ កងភូមិភាគពិសេស ។

ដានី ៖ ពូនៅហ្នឹងគេការពារកុំឲ្យអីនៅហ្នឹង?

រតនា ៖ ការពារទាំងអស់ កុំឲ្យមានប្រទេសណាមកឈ្លានពាន ទ្រទេសណាក៏ដោយ នៅព្រំដែនហ្នឹង ។

ដានី ៖ បាទ!

រតនា ៖ កាំភ្លើងតូច កាំភ្លើងធំតំរង់ទៅដីលាវនឹងឯង ។

ដានី ៖ ចុះមានដែលបានបាញ់គ្នា?

រតនា ៖ បាញ់ ១អាទិត្យ២អាទិត្យនឹងបាញ់ ។

ដានី ៖ បាញ់ជាមួយអ្នកណាទៅ?

រតនា ៖ បាញ់ជាមួយលាវនឹងឯងគ្មានបាញ់អ្នកណាទៀត បាញ់ ផងហើយខ្ញុំនេសាទត្រីផងទៅនេសាទត្រីហ្នឹងធ្វើប្រហុករាប់រយ ត្រីដឹកទៅកំពង់ធំមានតែ៣០០ពាន់ ៤០០ពាន់ ។

ដានី ៖ សំបូរត្រី?

រតនា ៖ បាទ! ធ្វើប្រហុកហ្នឹងដឹកទៅវេទ្ធន៍កំពង់ធំហ្នឹង៣ខែ ដែលខ្មែរក្រហមព័ទ្ធមួយជាន់ ព័ទ្ធមួយជាន់ម៉ោបារ៉ាកងទាហានលន់ ណុលហ្នឹងមួយជាន់ ហើយខ្មែរក្រហមដាក់មួយជាន់ក្រោមទៀត វាបីជាន់ដូច្នេះវាអត់មានអីទេ ដាច់ស្បៀងដាច់អាហារហ្នឹងពួកខ្ញុំហ្នឹង មេបញ្ជាការគេឲ្យ ធ្វើប្រហុកធ្វើអីផង ការពារព្រំដែនផង អាពួកនិសាពួកដឹកជញ្ជូនហ្នឹងពួកក្រុមដឹកជញ្ជូនគេដឹកយកទៅកំពង់ធំ ។

ដានី ៖ ចុះគេហៅកន្លែងអីគេបានសំបូរត្រីម្ល៉េះ?

រតនា ៖ កន្លែងហ្នឹងអាកន្លែងព្រែកហ្នឹងគេហៅទន្លេល្ពៅហ្នឹង ចេញពីទន្លេមេគង្គម៉ោព្រែកហ្នឹងវាធំដែរណាំប្រហែលទទឹង១០០ម៉ែត្រ ប៉ុនមានក្បាលណានោះ៥០-៧០-៨០ម៉ែត្រ ដាក់អាខាងព្រួល ដាក់ទ្រូ ដាក់លោប បិទជិតហើយអញ្ចឹហទៅ ត្រីវាបុកចូលក្នុងទ្រូ ហ្នឹង ។

ដានី ៖ ត្រីចូលច្រើន?

រតនា ៖ លើក១ដងមានតែ១តោន ២តោន ច្រើនមែនទែនត្រី ។

ដានី ៖ ប៉ុណ្ណាក៏មានដែរ?

រតនា ៖ ប៉ុណ្ណាក៏មានដែរ ធ្វើប្រហុកជញ្ជូនឲ្យគេ ត្រីឆៀតត្រីអី កាលខ្ញុំនៅហ្នឹងចាប់ពីព្រំដែនថៃភ្នំដងរែកវាពុះអាទន្លេមេគង្គហ្នឹង ដល់ដីលាវហ្នឹងវៀងចន្ទហ្នឹងវាឆ្លងមកទៀតភ្នំហ្នឹង ឆ្លងម៉ោទៀតម៉ោខាងនេះថៃ អានេះលាវ អាទន្លេហ្នឹងកាត់ពាក់កណ្តាល ពុះពាក់ កណ្តាល ។

ដានី ៖ ពុះពាក់កណ្តាល?

រតនា ៖ បាទ!ពាក់កណ្តាលទេ ហើយពួកខ្ញុំការពារទឹមព្រំដែនទៅព្រះនង្គ័ល ។

ដានី ៖ ទៅព្រះនង្គ័ល?

រតនា ៖ បាទ!

ដានី ៖ ចុះកន្លែងសាលាជួបជុំមិត្តអីហ្នឹង?

រតនា ៖ ហើយកាលខ្ញុំនៅហ្នឹងអត់មានប្រជាជនទេ ។

ដានី ៖ អត់មានប្រជាជនទេ?

រតនា ៖ បាទ!គេជម្លៀសអស់ គេជម្លៀសយកទៅណាអស់ហើយមិនដឹងរឿងផង ។

ដានី ៖ ឆ្នាំ៧០ហ្នឹង?

រតនា ៖ ៧២ ៧០នៅ ៧២គេជម្លៀសចេញហើយ ។

ដានី ៖ ហើយម៉េចទៀតទៅ បន្ទាប់ពី៧២ហ្នឹង?

រតនា ៖ ដល់គេវ៉ៃយួន ហើយវ៉ៃកំពង់ធំអាចេនឡាទី២ ហើយចេនឡាទី១ អាចេនឡាទី១មៅ វ៉ៃផ្តាច់ ហ្នឹងផ្តាច់ កង១របស់គេហើយ ខ្មែរក្រហមហ្នឹង?

ដានី ៖ ខ្មែរក្រហមវ៉ៃផ្តាច់ ឬពួកលន់ ណុល វ៉ៃផ្តាច់ពួកចេនឡាទី១?

រតនា ៖ អត់ទេ!នែ៎ខ្មែរក្រហម វ៉ៃផ្តាច់ជាកង១ រួចហើយបានអាមេរិចកាំងហ្នឹងគេផ្ញុំទ័ពហ្នឹង គាំឡើងអាចេនឡាទី២ទៀត បាទ!ចេនឡាទី២ទៀតវ៉ៃផ្តាច់ទៀត អាចេនឡាទី២ហ្នឹង ពិសេសមែនទែនហើយអាហ្នឹង វ៉ៃមែនទែនអានោះវ៉ៃបន្ទូរឈាម ដល់វ៉ៃដាច់ទៀត ដូច្នេះរៀបទ័ពតាមជាយដែន រៀបម៉ោបានឆ្នាំ៧២-៧៣ ៧៣ហ្នឹងគាំងពុំមានចាប់ លិចចាប់កើត ប្រធានកងពលអ្នកឲ្យចាប់ ។

ដានី ៖ ឆ្នាំណាហ្នឹង?

រតនា ៖ ៧៣ ។

ដានី ៖ ៧៣គេចាប់ប្រធានកងពល?

រតនា ៖ បាទ!

ដានី ៖ ចុះមេបញ្ជាការពូឈ្មោះអី?

រតនា ៖ មេបញ្ជាខ្ញុំឈ្មោះៗ ជុន ។

ដានី ៖ ឈ្មោះ ជុន?

រតនា ៖ បាទ!ជុនហ្នឹងអត់មានខ្មែរទេ ពួកជនជាតិចារាយ ។

ដានី ៖ ជនជាតិចារាយ?

រតនា ៖ បាទ! ប៉ុនចេះខ្មែរប៉ែឡាំមៗ ដែលគេតស៊ូតាំងពីឆ្នាំ៦៥ ៦៥រហូតមកដល់ម៉ោឆ្នាំ៧០ ម៉ោគេបានធ្វើធំ ដូច្នេះអាខ្មែរអីហ្នឹងនៅតែរងគេទេ មេៗកងពលគេហ្នឹងគេសុទ្ធតែពួកគេទាំងអស់ធំ អាពួកប្រែអាពួកអីគេនេះ ត្រចៀករហែករយារយៃពួកអស់នោះ ត្រចៀករហែកអស់ហើយ ដាច់ដាក់ត្បូងដាក់អី ដាក់ក្ពុកដីរ ។

ដានី ៖ កងពលហ្នឹងអត់មានលេខទេ?

រតនា ៖ កងពលហ្នឹងលេខប៉ុន្មានទេខ្ញុំភ្លេចបាត់ហើយ លេខហ្នឹងដូចជាជា៧០០ប៉ុន្មានទេ ដឹងតែកងភូមិភាគពិសេស វាមានដែរកងពលហ្នឹងខ្ញុំភ្លេចបាត់ហើយ ។

ដានី ៖ បន្ទាប់ពីវៀចេនឡាដាច់ឆ្នាំ៧២ហ្នឹងហើយចូលឆ្នាំ៧៣ហ្នឹងយ៉ាងម៉េច?

រតនា ៖ ដល់ឆ្នាំ៧៣ហ្នឹងម៉ោខ្ញុំក៏គេចាប់លិច ចាប់កើតមកខ្ញុំរហូតម៉ោគេឲ្យមក ហើយគេឲ្យម៉ោធ្វើស្រែវិញ គេដកកងទ័ពខ្ញុំម៉ាកងធំហ្នឹងឲ្យម៉ោធ្វើស្រែ ។

ដានី ៖ ធ្វើស្រែនៅ?

រតនា ៖ ធ្វើស្រែនៅហ្នឹងឯង ។

ដានី ៖ នៅណា?

រតនា ៖ នៅព្រំដែនលាវហ្នឹងឯង ។

ដានី ៖ ព្រំដែនលាវហ្នឹង?

រតនា ៖ បាទ! ធ្វើម៉ោក្រោយនេះ ។

ដានី ៖ ចុះគេវៀចេនឡានៅកំពង់ធំហ្នឹងយ៉ាងម៉េចពួកកងទ័ព ពួកពូគេដកម៉ោហ្នឹងដែរឬក៏អត់ទេ?

រតនា ៖ ពួកខ្ញុំអត់ដកទេ គេដកតែអ្នកខាងក្នុង ។

ដានី ៖ ម៉េចបានពូដឹងថាគេវៀចេនឡាគេអត់ដកអ្នកខាងក្នុង?

រតនា ៖ ចុះបើមេបញ្ជាការគេប្រាប់ ។

ដានី ៖ មេបញ្ជាគេប្រាប់?

រតនា ៖ កងធំៗគេប្រាប់ម៉ោ ដល់ឲ្យខ្ញុំម៉ោធ្វើស្រែបានប៉ុន្មានប្រហែលជា៧៣,៧៤ធ្វើស្រែហ្នឹងយកស្រូវឲ្យគេហ្នឹងឯង ។

ដានី ៖ ម៉េចបានគេដកឲ្យទៅធ្វើស្រែ?

រតនា ៖ វាអត់មានបាយហូប ។

ដានី ៖ អត់មានបាយហូប?

រតនា ៖ បាទ!

ដានី ៖ បាយយើងផ្តត់ផ្គង់ខ្លួនឯង?

រតនា ៖ បាទ! បាយយើងធ្វើហូបខ្លួនឯង គ្រប់កងទាំងអស់ គេថាម្ចាស់ការរៀងខ្លួន ខ្លួនទប ត្តម្ពខ្លួន ខ្លួនម្ចាស់ការលើខ្លួន ខ្លួនពឹងលើខ្លួនឯង នៅនេះមេបញ្ជាការគេប្រាប់ម៉ោ ហើយខ្ញុំទទួលហើយថាអត់មានបញ្ហាទេ អារឿងស្រែនោះ ម៉ាគ្នាខ្ញុំប៉ុន្មានហ្នឹងអាច ចិញ្ចឹមរស់ហ្នឹងឯង ចុះក្របីគោនៅច្រើននោះ ចាប់គោចាប់ក្របីហ្នឹងធ្វើ អាហ្នឹងគេ ជម្លៀសតែប្រជាជន តែគោក្របីនៅពប្រាក់ពព្រើត ធ្វើស្រែៗបានមួយឆ្នាំ៧៤ ដើម ឆ្នាំ៧៥អាហ្នឹងគេចាប់ ចាប់ភូមិភាគខ្ញុំហ្នឹងឯង ។

ដានី ៖ ចាប់ពីណាគេ?

រតនា ៖ ចាប់តា ហង់ ហ្នឹង ។

ដានី ៖ ឆ្នាំប៉ុន្មាន?

រតនា ៖ ឆ្នាំ៧៥ អាហ្នឹងរំដោះហើយណា៎ រំដោះហើយបានចាប់ ។

ដានី ៖ រំដោះហើយបានគេចាប់?

រតនា ៖ បាទ!

ដានី ៖ ម៉េចបានគេចាប់?

រតនា ៖ គេថាគាត់ក្បត់ កងទ័ពពួកខ្ញុំនេះប្រុងគិតកែប្រែទៅសេរីណា៎ មានក្រហមដែរណា៎ តែការងារក្រហមពេញ ប៉ុន្តែពួកគេញអេស៊ីអាហ្នឹងគេថាក្បត់ គេធ្វើៗទាំងខែល ប៉ុន្តែ ការគិតលាក់កម្លាំងបានច្រើនដែរហ្នឹង តាហង់លាក់កម្លាំងបានច្រើនណាស់នៅព្រៃស្អាក ឯណានោះមានប៉ុន្មានកងពលទៀតនោះ ។

ដានី ៖ ចុះតាហង់គាត់នៅកន្លែងមន្ទីរគាត់កន្លែងណា?

រតនា ៖ នៅស្រុកល្វាង ។

ដានី ៖ នៅស្រុកល្វាង?

រតនា ៖ ចេញពីកំពង់ធំទៅស្រុកល្វាងហើយ ចេញពីតាមផ្លូវហ្នឹងទៅស្រុកល្វាងហើយ ចេញ តាមផ្លូវហ្នឹងឯង ទៅផែបទៅកំពង់ស្រឡៅ ។

ដានី ៖ មន្ទីរគាត់នៅស្រុកល្វាង?

រតនា ៖ បាទ!

ដានី ៖ គេហៅមន្ទីររបស់?

រតនា ៖ មន្ទីរ គាហាង់ ។

ដានី ៖ មន្ទីររបស់ភូមិភាគពិសេសហ្នឹង?

រតនា ៖ បាទ!

ដានី ៖ ហើយចុះកាលនៅធ្វើការជាមួយគាហាង់ហ្នឹងកងទ័ពរបស់គាហាង់មានឈ្មោះអីខ្លះ?

រតនា ៖ កាលហ្នឹងមានឈ្មោះម៉ាន អនុស្សីគេទេភ្លេចហើយដូចមានតែពីរហ្នឹងទេ ។

ដានី ៖ តំបន់១០៣អីមែនទេ?

រតនា ៖ មិនដឹងតំបន់១០៣មែនទេ គ្រូអើយមានបានសើបៗណា ខ្ញុំភ្លេចដែរហ្នឹង ។

ដានី ៖ បាទ!អញ្ចឹងពូមានតួនាទីអីដែរកាលហ្នឹង?

រតនា ៖ ខ្ញុំធ្វើកងធំ ។

ដានី ៖ ទាហានកងធំ?

រតនា ៖ បាទ!

ដានី ៖ អញ្ចឹងចូលឆ្នាំ៧៩ហ្នឹងគេចាប់គាហាង់?

រតនា ៖ បាទ!

ដានី ៖ ឆ្នាំ៧៩ហ្នឹងយ៉ាងម៉េចដើមខែឬក៏ចុងខែ?

រតនា ៖ ដើម រំដោះបានប៉ុន្មានខែទេចាប់ ដល់ពេលចាប់គាហាង់រួចអាមេបញ្ជាការគេម៉ោខាងមួយទៀតគេចុះម៉ោចាប់បន្តបន្ទាប់ទៅមានឡើងមួយហើយ ។

ដានី ៖ ចាប់បានឈ្មោះអី?

រតនា ៖ ខ្ញុំអត់ដឹងផង ។

ដានី ៖ កាលហ្នឹងដល់ពេលគេចាប់អញ្ចឹងហើយពូនៅព្រំដែនដដែល?

រតនា ៖ ខ្ញុំនៅព្រំដែនដដែល ដល់ពេលចាប់គាហាង់បានប្រហែលជាកន្លះខែ ឯកសារពួកហ្នឹងម៉ោទៀតហើយពួកនិរសារគេឲ្យម៉ោឲ្យគ្រប់កងធំ គេសុំអញ្ជើញឲ្យម៉ោរៀននៅមន្ទីរភូមិភាគ មន្ទីរភូមិភាគនៅឯសៀមរាបនេះ ។

ដានី ៖ មន្ទីរភូមិភាគនៅសៀមរាប?

រតនា ៖ បាទ!

ដានី ៖ អាហ្នឹងគេមន្ទីរភូមិភាគអីគេ?

រតនា ៖ អាហ្នឹងមិនដឹងជាភូមិភាគអីគេទេ ព្រោះតែគេហៅភូមិភាគៗ មិនដឹងជាប៉ុន្មានខេត្តទេភាគគេហ្នឹង ។

ដានី ៖ ភូមិភាគខត្តរអីមែនទេ?

រតនា ៖ អត់ដឹងដែរ ។

ដានី ៖ ពីណាគេប្រធានមន្ទីរភូមិភាគ?

រតនា ៖ អត់ស្គាល់ទេ ។

ដានី ៖ ម៉ោរៀនភូមិភាគនៅសៀមរាប?

រតនា ៖ បាទ!ម៉ោរៀននៅសៀមរាប គេប្រមូលកងធំទាំងអស់ វរៈសេនាធំនៅព្រំដែនលាវ ហ្នឹង ។

ដានី ៖ ពីណាគេប្រធាននៅហ្នឹង?

រតនា ៖ ប្រធានវរៈសេនាធំ ឈ្មោះអយ ជនជាតិចារាយ សុទ្ធតែជនជាតិ ។

ដានី ៖ ម៉ាវរៈសេនាធំឲ្យម៉ោប្រជុំទាំងអស់?

រតនា ៖ បាទ!ឲ្យម៉ោប្រជុំទាំងអស់ ។

ដានី ៖ ចុះកងពល?

រតនា ៖ កងពលគេហៅម៉ោមុនអស់ហើយ អានេះនៅចលនាកងធំ ដូច្នេះគេប្រមូលកងធំម៉ោទាំងអស់ ម៉ោឡើងឡានៗពួកខ្ញុំអីហ្នឹងឡើងឡានគេទៅ ប្រមូលម៉ោគេអស់ហើយ ឡើងឡានម៉ោសៀមរាប គេថាម៉ោរៀន គេថាឲ្យយកខោអាវ១កំប្លេនឹងសៀវភៅ១ក្បាលនឹងប៊ិច១ម៉ោរៀន ហើយឡានម៉ោ៨ព្រឹកហ្នឹងគេទៅយកហើយ នាំគ្នាហូបបាយរួចក៏ឡានគេម៉ោយក ម៉ោយកក៏នាំគ្នាឡើងម៉ោ ដល់ឡានមកដល់សៀមរាប ចេញម៉ោពីម៉ោ៨-៩ព្រឹកមកដល់សៀមរាបម៉ោ៣យប់ជិតភ្លឺ ខ្ញុំស្មានតែម៉ោរៀនមែនទែន ដឹងអីផ្នែកនយោបាយគេអត់ដឹង ។

ដានី ៖ បាទ!

រតនា ៖ គិតទៅនយោបាយខ្មែរក្រហមជ្រៅណាស់ គេហៅថាទៅរៀននៅអគ្គការថ្នាក់លើ ។

ដានី ៖ បាទ!

រតនា ៖ ប៉ុនអាថ្នាក់លើហ្នឹងត្បូងចប បាទហ្នឹងហើយថ្នាក់លើ ។

ដានី ៖ គេហៅម៉ោម៉េចទៅ?

រតនា ៖ ដល់ហៅម៉ោមានអី ដល់ម៉ោអាកូននិរតីយកកាំភ្លើងបានភ្ជង់លើឡាន អាឡានដែ៏អាដវីទឹកអារបស់ចិនឡានទាហានគេហ្នឹង ដឹកពួកខ្ញុំម៉ោ ម៉ោដល់គេថាចុះៗពួកអាក្បត់ ខ្ញុំភ្ញាក់ខ្លួនបណ្តោយ ចុះពួកអាក្បត់ចុះៗពួកឯងនេះបាញ់បែកបន្ទះក្បាលឥឡូវហើយ ខ្ញុំថាស្រេចស្លាប់ហើយពួកយើងស្លាប់ហើយ ចុះពួកខ្ញុំមានអីពីណា អាវុធអត់មាននោះ មាន

តែដៃទទេ សៀវភៅ១ក្បាល ប៊ិច១ ខោអាវ១កំភ្លេហ្នឹងមានស្អី ចុះៗ ពួកខ្ញុំក៏ចុះទៅ ពិសេសឲ្យតំរង់ផ្លូវ ហើយអាមួយនិរតីគេចេញម៉ោភ្លេតម៉ោដល់ អាធ្វើធំណាស់អាហ្នឹង គេថាពួកឯងទាំងអស់បើមាសទឹក១០ សូម្បីតែទៅជិតភក់កប់ជ្រៅយ៉ាងណាលើកម៉ោ គឺនៅតែក្រហមដដែល ដូច្នេះគេថាពួកឯងទាំងអស់គ្នា ត្រៀមខ្លួនព្រឹកនេះគឺថា សំភារៈ បង្គី២ ចប១ លើកទំនប់ដីកប្រឡាយ ស្ពានស្រែក មេមាយហ្នឹង ។

ដានី : ស្ពានអី?

រតនា : ស្ពានស្រែក គេហៅស្ពានមេមាយ ។

ដានី : នៅណា?

រតនា : នៅស្រុកក្រឡាញ់ ខ្ញុំលើកនៅហ្នឹងឯង ហើយតែហានឆែបវៃចោល ។

ដានី : ហានអី?

រតនា : ឆែបចប ។

ដានី : ឆែបចបគេវៃចោល?

រតនា : បាទ!ឆែបចបគេវៃចោលហើយ ហើយថ្មមណាស់គ្រូអើយកាប់ ដីសុទ្ធអាដីគីបនោះ គេវាស់ឲ្យ ម៉ាគីបហ្នឹងហើយបាយ បាយគេឆ្នាំងអាម៉ាស៊ីនហ្នឹងចំហុយមាទឹក គេវាស់ ម៉ែត្រប៉ុន្មាន គេកាប់បាយពិតៗៗដាក់ចានមួយតឹកៗសមួមួយចាន ហើយបើមិនមា គីបហ្នឹងអត់បានបាយទេ អត់បានទេ ។

ដានី : បាទ!

រតនា : អាខ្លះហ្នឹងដីកវាស់ល្ងាចបានហើយ ដីកព្រែក ដីវាគ្រួស ។

ដានី : ដីថ្ម?

រតនា : បាទ!ថ្មតែហានធ្វើខ្លាំងឆែបចបគេវៃចោលហើយ ។

ដានី : បាទ!

រតនា : ដូច្នេះកាប់ថ្មមណាស់ កាប់តិចៗៗម៉េចនាយបាន ។

ដានី : គេប្រាប់ថា ឲ្យតែឆែបចបគេវៃចោល?

រតនា : បាទ!តែឆែបវៃចេលហើយ គេចោទថាខ្មាំងធ្វើបំផ្លាញរបស់គេ ហើយលើកកម្ពស់ខ្ពស់ មែនទែនហើយ វែកលើកចាក់ៗ ហើយប្រធានកងពលៗគេប្រជុំ ហើយឈឺប៉ុន្មាន ដេកពេទ្យប៉ុន្មានអីប៉ុន្មានហ្នឹងរាយការណ៍ឲ្យគេ ឈឺហ្នឹងបាយបានទេ តាមដាន ឈឺអា ត្រាក់រញោក់រញ៉ែរ គ្រុនញាក់គ្រុនញ័រគ្រុនបាយបាន គេថាអញ្ចឹងហើយ ហ៊ឺ!ខ្ញុំថាដល់

ហើយចុះអាគ្នាឈឺគ្រុនតិចតួចហ្នឹងបាយម៉េចបានគាត់ហូបបានហ្នឹងឯង ដូច្នេះអាណាគ្រុនទៅមិនរួចស៊ីបាយបានធ្វើដីលេខ១ នៅកន្លែងខ្ញុំលើកទំនប់ហ្នឹង មានប៉ុន្មានកងលើកទំនប់ ប៉ុន្មានកងធ្វើស្រែប្រាំង បាទបែកមុខព្រួញគ្នា ។

ដានី : គេចាប់បញ្ជូនម៉ោឲ្យលត់ដំនៅនេះហ្នឹងមានគ្នាច្រើនទេ?

រតនា : បាទ!ច្រើនគ្នាប៉ុន្មាន៣០០០នាក់ដាង ។

ដានី : ម៉ោពីព្រំដែនហ្នឹង?

រតនា : ម៉ោពីព្រំដែនទាំងអស់ តាំងពីព្រះនគ្គ័ល ខាងណាខ្លះទេច្រើនណាស់ ម៉ោគ្រប់កងឯកភាពសុទ្ធតែទាហានចាស់ម៉ោងាប់នៅសៀមរាប អាអណ្តូងចំការកៅស៊ូខាងកើតសៀមរាប ហ្នឹងបិទគ្របហ្នឹងវ៉ៃទម្លាក់ អត់មាននេះទេ អន្លុយតំរៀបជុំវិញអណ្តូងកូស១ចបហ្នឹងធ្លាក់ព្រួសទៅ ដាក់ទឹកហៀរព្រួលម៉ោ ដាក់ៗទាល់តែពេញទៅ បិទអាគំរបស៊ីម៉ង់គ្រប ភ្លីបដាក់មួយជួរៗ ចុះអណ្តូងកៅស៊ូហ្នឹងអណ្តូងគ្រប់ជួរ ដាក់ពេញអស់ហើយហ្នឹង អ្នកណាទៅធ្វើការមិនរួចឈឺហ្នឹង ល្ងាចបញ្ជូនទៅអន្លុការថ្នាក់លើ មុងហ្នឹងហើយ ។

ដានី : ស្លាប់ច្រើនអញ្ចឹង?

រតនា : បាទ!រស់តិចណាស់ ជាពិសេសត្រឹមវរៈសេនាតូច វរៈសេនាធំគេវ៉ៃចោលអស់ រស់ភាគតិច ដល់មកធ្វើស្រែ នឹងលើកទំនប់រួច ម្តងនេះដែនការគេឲ្យ ៧៥អើខែប៉ុន្មានទេរំដោះនោះថ្ងៃទីប៉ុន្មានលោកគ្រូ រំដោះពេញអាយួនចូល?

ដានី : ថ្ងៃទី៧ ខែមករា ឆ្នាំ៧៩ ។

រតនា : បាទ!ហ្នឹងហើយត្រូវហើយ ដល់នេះបញ្ចេញខ្ញុំពាកកងតូច ចេញឲ្យខ្ញុំម៉ោសំរោងធ្វើផ្លូវលំចេះ ពីសំរោងហ្នឹងទៅដល់ទល់ដែនខេត្តព្រះវិហារជាយដែន ។

ដានី : សំរោងណា?

រតនា : សំរោងចុងកាល់ហ្នឹង ។

ដានី : អ្ហូ!សំរោងខេត្តឧត្តរមានជ័យ?

រតនា : បាទ!ហ្នឹងហើយ ធ្វើនៅតាមជាយដែនហ្នឹង ធ្វើពីផ្លុងពីស្នាច់នេះទៅ ពីស្នាច់ទៅណាន់ តាវទៅតាមផ្លូវហ្នឹងឯង ធ្វើផ្លូវពីផ្លុង ពីឧត្តរមានជ័យទៅព្រះវិហារធ្វើបានពាក់ កណ្តាលធ្វើបានពាក់កណ្តាល ត្រង់ណាទេខ្ញុំភ្លេចហើយ មេបញ្ជាការគេឈ្មោះ អាសាយហើយពួកខ្ញុំមានគ្នា៣០០នាក់ ៣០០នាក់ហ្នឹងក្តាប់តែគាត់ហ្នឹងឯង ដល់ព្រឹកឡើងដាំបាយដាំអីរួច បែកមាំកងធំ១០០ម៉ែត្រ កាប់ចបហើយ សែងដាក់បង្គី

ហ្នឹងសែងចាក់ថ្នល់ ធ្វើៗៗកាត់ព្រៃកាត់ផ្សែទៅហើយ ព្រឹកឡើងគោរពទង់ជាតិរាល់ថ្ងៃហើយ ដល់ថ្ងៃហ្នឹងកំពុងតែគោរពទង់ជាតិហើយថ្ងៃយួនចូលហ្នឹង ដល់កំពុងតែគោរពស្រាប់តែម៉ាសន្ទុះហ្នឹង អាវិទ្យុត្រូគ្រប់វិទ្យុហ្នឹង បើកវិទ្យុគោរពទង់ជាតិ ដល់ហើយត្រូស្គរ ថោនឡើងគ្រាវក្នុងរ៉ាត់យ៉ូហ្នឹង ហ៊ឹបងជាន់ដើងខ្ញុំអីណា អាសយឡើងភ្នែកស យើស្អីទេ អ្នកណាចេះ ចាប់មិនបានអីមិនបាន ដល់ហើយគាត់ជិះម៉ូតូសំរោងនេះ ម៉ោដល់គាត់បកទៅវិញ គាត់ថាអ៊ូអត់បានទេពួកយើងយួនចូលឡើងពេញហើយ ថាបើអញ្ចឹងនែ៎ពួកយើងនៅនេះហើយ ចាំខ្ញុំទៅយកកាំភ្លើងមកបើកឲ្យ មកទប់ទល់យួនវិញ ខ្ញុំថាតែប៉ុននេះមានផ្លុងវិញហើយ ឈប់ផាប់ហើយ តែមានផ្លុងឈប់ផាប់ហើយ ដល់ហើយអាសាយគេម៉ោសំរោងនេះ គេយកកាំភ្លើង យកគ្រាប់កាំភ្លើង គ្រាប់បេម៉ោ មិនដឹងយកមកពីណាទេ ដឹកម៉ោទាំងកេះៗ អាកេះធំៗបេក៏បេ អាកាំភ្លើងធំៗ កាំភ្លើងតូចៗមានគ្រប់ធន់ ហើយហែកកេះចែកគ្នា១នាក់១ដើមៗ អ្នកណាកាន់កាំភ្លើងធំៗ អ្នកកាន់តូចៗទៅ បាទ!ដល់ហើយលាដោះៗ ដាក់ប្រេងដាក់ខ្លាញ់អីរួចចែកគ្រាប់ចែករំសេវហើយអស់ទៅ អាសាយថាល្ងាច យើងទៅទប់ទល់អូរជីក យួនដល់សៀមរាប បាត់ហើយចុយម៉ាយលឿនមែន ឲ្យម៉ោទប់ទល់អូរជីក ដល់នេះទៅអាមេៗពួកខ្ញុំហ្នឹងដែលតំណាងឲ្យទាំងអស់គ្នាថា ពួកយើងសុខចិត្តទៅវ៉ៃយួន ឬក៏យើងទៅប្រទេសថៃអាណាល្អជាងអាណា សង្គ្រាមយើងធ្លាប់ធ្វើហើយ ឥឡូវយើងទៅរករស់វិញ បើថាអ្នកណាទៅថៃលើកដៃ បើថាអ្នកណាមិនទៅកុំលើក ដល់នេះលើកដៃព្រាត ទៅថៃដល់ថាទៅថៃមានអី អាសាយឡើងម៉ូតូប្រែនម៉ោសំរោងនេះ វាខ្លាចចុះកាំភ្លើងគ្រប់ដៃអត់ហានបាញ់វាទៀតណា អត់ហានបាញ់វាទេ ។

ដានី : សាយ ហ្នឹងខាងនិរតី?

រតនា : និរតី កាចចុយម្រាយហើយ វ៉ៃសុទ្ធតែក្បាល ។

ដានី : វ៉ៃអីក្បាល?

រតនា : វ៉ៃក្បាលមនុស្ស ។

ដានី : យកអីវ៉ៃ?

រតនា : ដំបង គុលព្រីង ។

ដានី : វ៉ៃសម្លាប់ឬក៏វ៉ៃ?

រតនា ៖ វើសម្លាប់ គំរាម ខ្ចិលធ្វើការ ឈឺធ្វើពុតក្បត់អី ដាក់ភូសវើ គេថាទុកក៏មិនចំណេញដកចេញក៏មិនខាតម៉េចនោះ ។

ដានី ៖ បាទ!ចុះបន្ទាប់ពី ហន់ទៅ មានអ្នកនិរតីមកធ្វើធំច្រើនទេ?

រតនា ៖ អ្ហ៊ូ!ពេញទឹកពេញដី ។

ដានី ៖ គណៈភូមិភាគក៏អ្នកនិរតីដែរ?

រតនា ៖ ទាំងអស់ ។

ដានី ៖ ចុះដែលស្គាល់តាអ៊ីកងតាចាប ហៅសែ?

រតនា ៖ អាសាយ អាខែង អាសែ ហ្នឹងហើយស្រុកក្រឡាញ់ ។

ដានី ៖ ធ្វើខាងគណៈភូមិភាគ?

រតនា ៖ គណៈភូមិភាគអាសែ ហ្នឹងហើយ អាសែភូមិភាគសៀមរាបហ្នឹងឯង គណៈភូមិភាគអាសែហ្នឹងប្រធាន ឈ្មោះសែ អាហ្នឹងចាប់មុនគេហើយ ។

ដានី ៖ គេចាប់ដែរ?

រតនា ៖ បាទ!ចាប់ពីអាសែទៅ បានតាហន់ ។

អ្នកជិតខាង ៖ តំបន់ដែលគ្រប់គ្រងបន្ទាយឆ្មារមេធំវាងាប់ហើយ កាចណាស់អាហ្នឹងចង់ប្រលះស៊ីថ្លើមឈ្មោះ ម៉ាក់ៗ ។

ដានី ៖ ឈ្មោះ ម៉ាក់?

អ្នកជិតខាង ៖ បាទ!ឈ្មោះ ម៉ាក់ ងាប់ទាហានបាញ់ ស្រីៗចាស់ៗនោមដាក់ក្បាល គេងាប់ហើយយកពូថៅកាប់ ពួកខ្ញុំនាំគ្នាទៅមើល វាកាចណាស់អានោះ ។

ដានី ៖ ហើយចុះអើវាយ៉ាងម៉េចទៅពូ ពេលបន្ទាប់ពីលើកដៃហើយម៉ោ?

រតនា ៖ ពេលហ្នឹង ពួកខ្ញុំនេះត្រូវទៅថៃ កន្លែងផ្លូវស្លាប់នេះហើយ ព្រហើនណាស់នាំគ្នាដើរទៅមីនតាមផ្លូវអី ដូចជាទេវតាអញ្ចឹងដើរទៅអត់មានផ្ទុះទេ ជាន់អត់ផ្ទុះសោះមីន ដើរទៅទាហានដូចគ្នា គេអត់អីទេ ដល់ព្រំដែនស្លាប់ អាបន្ទាយចាស់គេនោះ ទៅដល់ជួប លោកភី ធឿនៗហ្នឹងគាត់ធ្វើខាងខ្មែរបារ៉ាប្រធានខាងស្តាំ ។

ដានី ៖ បាទ!

រតនា ៖ ដល់ទៅគេថា ពួកបងប្អូនយើងទាំងអស់គ្នា ទុកអាវុធនៅកន្លែងខ្ញុំទាំងអស់ ហើយអ្នកឯងទៅប្រទេសទី៣ ទៅប្រទេសទីប៉ុន្មានក៏ទៅចុះ ហើយគាត់និយាយទៅថៃ និយាយទៅណាទៅណីទេ គាត់ធ្វើទាហានដូចមិនដឹងរឿង គាត់នៅនឹងឡាក់នឹងហើយ ។

ដានី ៖ បាទ!

រតនា ៖ ហ្នឹងហើយបា៉រ៉ាឡើងពព្រិកពព្រើតហ្នឹងហើយ មើលលិចពេញតែភ្នំ ។

ដានី ៖ បាទ!

រតនា ៖ ពួកខ្ញុំមានអីឆ្លងអាម្រះទៅភ្លុចទៅ នាំគ្នាដើរចូលទៅ ដល់អារថក្រោះថៃ អមសងខាង ម៉ោពួកខ្ញុំដើរប្រឡោះកណ្តាលទៅប្រទេសថៃ ចូលទៅដល់ប្រទេសថៃ ម៉ោដល់អាមន្ទីកាបដើងហ្នឹង ម៉ោដល់ហ្នឹងខ្ញុំជាប់គុកថៃហ្នឹង២អាទិត្យទៀត ថៃដាក់គុកខ្ញុំ ដល់ដាក់ទៅគ្នាវាច្រើនពេកដាក់អត់បាន យកអារបងលួសដាក់ហ៊ុំជុំវិញអាបន្ទាយហ្នឹង ។

ដានី ៖ ជាប់គុក២អាទិត្យ?

រតនា ៖ បាទ!ឲ្យដេកនៅដីទៀត ប៉ុនស៊ីម៉ង់ គ្មានកន្ទេលគ្មានអីក្រាល ។

ដានី ៖ ហើយម៉េចទៀតទៅ?

រតនា ៖ បាទ!ដល់បាន២អាទិត្យហ្នឹងក៏ មានពួកកាកបាទគេទៅសម្ភាសន៍ពួកខ្ញុំនៅនោះទៀត កាកបាទក្រហមថៃនេះ មិនដឹងខាងណាខ្ញុំមិនសូវស្គាល់គេផង គេម៉ោសម្ភាសន៍ថាធ្វើអី ខ្ញុំថាធ្វើកងចល័ត ហើយចុះថៃឲ្យអីហូបអង្ករយ៉ាងណាអីយ៉ាងណា ហើយគេយកអង្ករឲ្យមើលយកត្រីខ មើលទៅហើយគេថាអត់ល្អ ហើយខ្ញុំទៅយកអង្ករវានោះយកទៅឲ្យ ចែកឆ្អិល ចែកសាប៊ូ ចែកម៉ុង ចែកភួយ ចែកអីៗ ចែកច្រាស់ដុសធ្មេញ ចែកអីៗ គ្រប់កំប្លេម៉ាប្រដាប់ប្រដារប្រើប្រាស់ ខ្ញុំថាបណ្តឹងបានរស់ហើយខ្ញុំ ដល់នេះក៏ថាបងប្អូនណាចង់ទៅខេត្តព្រះវិហារ អាហ្នឹងអង្គការមេបា៉រ៉ា មែនមេបា៉រ៉ាទេ ចៅហ្វាយខេត្តនៅស្រុកថៃហៅថា អំពើខាន់ថាឡាក់ ខេត្តស៊ីសាកេត ព្រំដែនមុខខេត្តព្រះវិហារ អ្នកណានៅខេត្តកំពង់ធំ អ្នកណានៅសៀមរាប អ្នកណានៅណាឲ្យលើកដៃ ខ្ញុំដឹកយកទៅនៅព្រំដែនធ្វើអាសាសម៉ាក់ថៃ ខ្ញុំធ្វើអាសាសម៉ាក់ថៃទៀត បាទ!ហៅណាយៗ ឈ្មោះ យិនឌី ខ្ញុំទៅនឹងគេហ្នឹង ហើយដឹកឡានទៅដល់ព្រែកគន្ធា ទៅដល់គេបំពាក់កាំភ្លើង បំពាក់អាវុធ ទៅទល់មុខប្រាសាទ ឲ្យទៅនៅមុខប្រាសាទនឹងហើយ បាទទៅដល់ហ្នឹង ក៏អាពួកយួនទៅដល់ប្រាសាទហ្នឹងហើយ ចូលពេញអាប្រាសាទហ្នឹងអស់ ឃើញ ពួកខ្ញុំនិយាយខ្មែររវេះរវស់ហ្នឹងលើកដាក់បាញ់ហើយ ហើយថៃក៏មែនអី កាបា៉ល់ហោះក៏ម៉ោ អាអីក៏ស្បែកជើងរថក្រោះម៉ោៗឡើងគគ្រឹសនៅមុខប្រាសាទ នឹងឯង ។

ដានី ៖ ប្រាសាទព្រះវិហារ?

រតនា ៖ បាទ!យកកូនអាមេក្រូ អាកូនតូចហ្នឹងសម្រាប់និយាយហ្នឹង និយាយតជាមួយគេថាកុំបាញ់ កូនខ្មែរហ្នឹងគឺសុទ្ធតែអាសាសម៉ាក់ថៃទេ ។

ដានី ៖ អ្នកណាជាអ្នកនិយាយ?

រតនា ៖ ណ្ហូកខ្ញុំទាំងអស់គ្នាហ្នឹងហើយ ។

ដានី ៖ និយាយទៅណា?

រតនា ៖ និយាយទៅឲ្យពួកយួន ទៅប្រាសាទ បាទ!និយាយពីអាឡាក់ខ្មែរយើងនេះ ។

ដានី ៖ និយាយភាសាខ្មែរយើងហ្នឹង?

រតនា ៖ និយាយភាសាខ្មែរ ចុះវានិយាយភាសាខ្មែរតែប៉ប៉ែសហ្នឹង ថាយើងឈប់បាញ់គ្នាទៅ សុទ្ធតែសាសម៉ាក់ថៃទេ មកការពារនៅជាយដែននេះឈប់បាប់ ហើយក៏ឈប់បាញ់ ទៅទៅវិញទៅ ហើយខ្ញុំក៏នៅធ្វើនៅហ្នឹងបានប៉ុន្មានខែទេ ក៏គេឲ្យចុះមកខ្មែរទៀត មកយកពត៌មាននៅប្រទេសខ្មែរយ៉ាំងណាៗ ដល់ខ្ញុំចុះម៉ោក៏រកកន្លែងឡើងទៅវិញអត់ រួចខ្ញុំក៏ធ្វើប៉ារ៉ានៅទីនេះជាមួយគេនៅក្រោមទៀត ។

ដានី ៖ ឆ្នាំណាហ្នឹង?

រតនា ៖ អាហ្នឹងឆ្នាំ៩០ប៉ុន្មានទេ សម័យគេធ្វើនៅជុំវិសាយធូរនេះ ។

ដានី ៖ បាទ!ខាងថៃគេឲ្យពួចុះមកយកពត៌មាន?

រតនា ៖ បាទ!មកយកពត៌មាន ម៉ោគេដឹកគេពង្រាត់ឲ្យចូលសាយធូរ ។

ដានី ៖ យកពត៌មានអីគេហ្នឹង?

រតនា ៖ យកពត៌មានដូចថាយួនហ្នឹងវាចូលប្រទេសខ្មែរ វាធ្វើបាបប្រជាពលរដ្ឋយ៉ាំងណាអីយ៉ាំងណា ឲ្យតាំងពីអប្រិយថត ឲ្យតាំងពីស្អីៗទាំងអស់ ថតឲ្យគេ ។

ដានី ៖ ថៃអាហ្នឹងថៃ?

រតនា ៖ ថៃ ប្រាក់ខែ ម៉ាខែ១៨០០ ។

ដានី ៖ ១៨០០បាត?

រតនា ៖ បាទ!

ដានី ៖ ឲ្យថតតែរូបទេ?

រតនា ៖ បាទ!ថតតែរូបទេ ដល់ហើយខ្ញុំមិនបានទៅវិញ ក៏ធ្វើប៉ារ៉ានីងគេហ្នឹង ។

ដានី ៖ អត់ត្រឡប់ទៅវិញ?

រតនា ៖ អត់!

ដានី ៖ ម៉េចបានអត់ត្រឡប់?

រតនា ៖ វាបែកបាក់គ្នាអស់លោកគ្រូ ម៉ោគ្នា១២នាក់ហ្នឹង អាខ្លះម៉ោទៅបានប្រពន្ធ ចាប់កូនក្រមុំគេពេញតែស្រុក ពេញតែស្រែយូរទៅបាត់គ្នាអស់ នៅតែខ្ញុំម្នាក់ឯង ឃើញប៉ាវ៉ាគេពព្រាក់ពព្រើតចូលគេទៅ ។

ដានី ៖ បាទ!

រតនា ៖ ក៏ចូលធ្វើប៉ាវ៉ាគេទៅ ធ្វើបានប៉ុន្មានឆ្នាំ ប្រហែលបានមួយឆ្នាំដាង គេឲ្យទៅរៀននៅបន្ទាយអំពិល ។

ដានី ៖ ស្រុកបន្ទាយអំពិល?

រតនា ៖ បាទ!បន្ទាយអំពិលកាលហ្នឹងប្រធាន ឌៀង ដែល ជាមេបញ្ជាការនៅហ្នឹង បើកស៊ីអីបង្រៀនចំប៉ាញ ប្រមូលទី២ រៀនហ្នឹងគឺថាគ្នា៦០០នាក់ ចូល ឌៀង ដែល គេថា ៦០០សល់តែ៣ក៏យក ចុះអា៣ទៀតទៅណា? អា៣ហ្នឹងគឺថាងាប់ សាលាយោធឹមយោធឹមគឺច្បាប់ៗ ប្រវ៉ាក់ហ្នឹងដាក់នៅដីទៀតខ្វេងទ្វាហ្នឹង គ្រាន់តែដើរកន្ទេងអត់បានទេ កន្ទេងងាប់ហើយ ច្បាប់គឺងណាស់គ្រូអើយរៀនស៊ីអី ទាហានសព្វថ្ងៃបើថាបានរៀនច្បាប់ស៊ីអីហ្នឹងគឺថាដឹងតែដឹងហើយទុក្ខធុរៈម៉េចអីម៉េចដឹងហើយ ច្បាប់ជាមួយប្រជា ពលប្រើរបៀបម៉េចអីម៉េច ខ្ញុំរៀនហ្នឹងអត់មាននេះទេ គឺដូចច្បាប់កាលពីសម័យ សីហនុពីសម័យសាធារណៈរដ្ឋនេះឯង ។

ដានី ៖ បាទ!

រតនា ៖ ច្បាប់ហ្នឹង!បើគ្រូៗវិញសុទ្ធតែសក្តិ៣ សក្តិ៤ គ្រូដែលបង្ហាត់ហ្នឹង អាខ្លះសក្តិ៣ បង្រៀន អាខ្លះសក្តិ៥បង្រៀន ដើងទឹក ដើងគោក ដើងអាកាស អ្វីកាចៗអស់ទាស់ ហើយ អាណាធ្វើខុស អាណាចោលកន្ទុយបារីអីតាមកន្លែងបរិវេណអីហ្នឹង វាវអាចម៍ជ្រូកមួយថ្ងៃវាស់ល្ងាចនោះ ក្នុងប្រឡាយអាចម៍ជ្រូកហ្នឹងទឹកស្មើនេះវាវនៅវាវហ្នឹង ឯង ។

ដានី ៖ វាវធ្វើអី?

រតនា ៖ វាវមីន ទោសរបស់គេ អ្នកខុសច្បាប់ ហើយរៀននៅបន្ទាយអំពិល អ្នកណាខ្លាំងចង ដៃចេះ ហូបបាយណាបាន សម្លហើយបាយដួសដាក់មាត់ចេះ បឺតនឹងមាត់បណ្តើរហើយខាំៗហូប ។

ដានី ៖ ម៉េចបានដឹងអញ្ចឹង គេរៀន?

រតនា ៖ បាទ!រៀនហាត់ គេខទាហរណ៍បើខ្ញុំឆចាប់បាន តែបាយគេមិនឲ្យស៊ីធ្វើណាបាន ធ្វើណាតែគេនាំទៅ អោនខាំ អ៊ូ!ច្បាប់គឹងណាស់ស៊ីអីៗគឹងមែនទែន ដល់ខ្ញុំរៀនចប់មិនវគ្គទៅមានសញ្ញាបត្រ មានអីមានកាំភ្លើងខ្លី មានអីគេបើកឲ្យកំប្លេម៉ោ បានម៉ោកាន់ប៉ាវ៉ានៅជំរុំអូរបួកនេះទៀត ។

ដានី ៖ កាលហ្នឹងតួនាទីរបស់ពូ?

រតនា ៖ តួនាទីប្រធានកងធំ កងធំទៀត ខ្មែរក្រហមក៏បានធំ ម៉ោប៉ាវ៉ាក៏បានធំទៀត រៀនមានសញ្ញាបត្រ រី សារ៉េត ប្រធានកងពលខ្ញុំហ្នឹងម៉ោយកខ្ញុំ២-៣ដងហើយ ប៉ុនប្រពន្ធខ្ញុំអត់ឲ្យទៅ ឲ្យទៅបំពាក់សក្តិ៤ប៉ុនខ្ញុំអត់ទៅខ្ជិល ។

ដានី ៖ ម៉េចអញ្ចឹង?

រតនា ៖ ខ្ញុំរបៀបចាញ់បោកគេដែលវ៉ៃហ្នឹង?

ដានី ៖ យ៉ាងម៉េច?

រតនា ៖ វ៉ៃនៅថ្មពួក វ៉ៃដាច់ឲ្យរង្វាន់១៥ម៉ឺនលោកគ្រូ រថក្រោះបើអ្នកណាបាញ់ឈ្នះមួយគ្រឿង១៥ម៉ឺន រថក្រោះខ្ញុំកាន់ពីរមុខ កាន់អាម៉ាវ៉ាសបាញ់រថក្រោះមួយ អារថក្រោះហ្នឹង ខ្ញុំរៀនខ្ទីកខ្ទីអស់ហើយ អាចំងាយប៉ុន្មានៗ បាញ់ខាងណាៗខ្ញុំដឹងអស់ហើយ អារថក្រោះបន្ទាយឆ្មាហ្នឹងគេវ៉ៃនៅបន្ទាយឆ្មានេះ គេវ៉ៃកណ្តុរនេះ អាមួយហ្នឹងមានទៅណានៅជាប់ផុងនៅនេះទៅអត់រួច ទៅរួចបានខ្ញុំដាក់បាត់ បានបាញ់ហ្នឹងបាញ់អាក្នុងប្រាសាទ សុទ្ធតែថ្មពួក អាកងពលវាទៅនៅខាប់នៅហ្នឹងឯង ។

ដានី ៖ រថក្រោះៗខាងណា ខាងវៀតណាម ឬខាងរដ្ឋកម្ពុជា?

រតនា ៖ រដ្ឋកម្ពុជាទេរថក្រោះហ្នឹង មិនមែនរបស់យួនទេ បាទនៅនេះបន្ទាយឆ្មានេះគេបាញ់ឆេះអស់២ អាមួយរថទៅថ្មពួក ។

ដានី ៖ អ្នកណាគេ អ្នកឲ្យរង្វាន់?

រតនា ៖ ទៅអាមេរិចអស់ហើយ អាដែលលួចក្បាលអ្នកតា ។

ដានី ៖ ខាងណាជាអ្នកលួច?

រតនា ៖ លោក ដែង ឈ្មោះ ដែង ។

ដានី ៖ អាហ្នឹងខាងណា?

រតនា ៖ ដែង ហ្នឹងខាងភូមិភាគ១លោកធំ មេបញ្ជាការវ៉ៃម៉ា ។

ដានី ៖ ខាងប៉ាវ៉ា?

រតនា ៖ បាទ!ខានប៉ាវ៉ា ហ្នឹងយើងចាញ់ប្រៀបគេហ្នឹងហើយ ។

ដានី ៖ គេប្រាប់ថាបាញ់ឈ្នះគេឲ្យ១៥ម៉ឺនបាត?

រតនា ៖ បាទ!ហើយវ៉ៃសមរភូមិដូចគ្នា អាពួកថ្មពួកនោះ១៥ថ្ងៃដាច់ហើយ វ៉ៃដាច់ខ្ញុំសម្រាក បាន១ថ្ងៃ សម្រាកទឹមបាន១ថ្ងៃគេគេម៉ោទៀតហើយ បន្ទប់ខ្ញុំ៤២ ហើយខលម៉ោ ៤២ៗ ខ្ញុំថាទទួលបាន ឥឡូវសុំកូនៗហ្នឹងរៀបចំកម្លាំងឡើងវ៉ៃទ្រេសទៀត ទ្រេសថ្ម ពួកនេះ ខ្ញុំក៏រៀបចំកម្លាំងឡើងម៉ោទៀតហើយ វ៉ៃដាច់ម៉ោ១២បានដាច់ វ៉ៃតាំងពី ម៉ោង៤ព្រឹក វារសេៗអស់ទាស់ហើយ បាញ់ៗៗបាញ់អស់គ្រាប់បានខ្ញុំចូល វ៉ៃ ទ្រេស ឲ្យដាច់នេះបានអា៤២កាណុងខានហ៊ុន សែន ម៉ោបណ្តោយ ។

ដានី ៖ ៤២កាណុងហ្នឹង?

រតនា ៖ បាទ!ម៉ោដល់ថ្នាក់តាកេះនេះ ថ្មពួក៤២-៤៣ ដាច់១ដងហើយរត់ ប៉ាវ៉ារថដែលហ្នឹង អា៤២ដាក់លាន់ហ៊ូងៗ រកកន្លែងទាក់អត់ឃើញទេ បាញ់ហើយ មិនដឹងម៉េចរថទៅរក ខ្មែរក្រហម ឯងខំជួយដែល ។

ដានី ៖ ជួយប៉ាវ៉ា?

រតនា ៖ បាទ ហើយវាក៏ទៅស្វាយវិញទៅ ។

ដានី ៖ ពីណាទៅស្វាយ?

រតនា ៖ អាកាំភ្លើងធំហ្នឹងឯង ។

ដានី ៖ អា៤២?

រតនា ៖ អា៤២កាណុង ។

ដានី ៖ រត់ទៅវិញដែល?

រតនា ៖ រត់ទៅវិញ ។

ដានី ៖ ចុះខាង ញឹម ប៊ុនឆៃ គាត់នៅហ្នឹងដែរឬអត់?

រតនា ៖ ញឹម ប៊ុនឆៃ គាត់នៅផ្សេង នៅលើភ្នំនោះ លោកធំដែលបញ្ជាហ្នឹងគាត់នៅលើភ្នំទាំង អស់ ។

ដានី ៖ លើភ្នំណា?

រតនា ៖ នៅភ្នំចេក នោះអាថ្មសៗនោះ ។

ដានី ៖ ពីណាគេ ជែង អីហ្នឹង?

រតនា ៖ ជែង ហ្នឹងលោកធំគេហ្នឹង នៅចាំតែស្តាប់វិទ្យុ នឹងបញ្ជានឹងឯង ។

ដានី :	ដែន ហ្នឹងហើយលោក ប៊ុត រីឆៃនៅជាមួយគ្នា?

រតនា :	បាទ!នៅទាំងអស់នៅហ្នឹង ធំៗគ្មានចុះម៉ោទេ ចុះម៉ោបានតែប្រធានកងពលអីទេ ហើយវរៈសេនាតូច វរៈសេនាធំនៅលើដែរ ចុះម៉ោតែអាតូច ម៉ោអនុអីហ្នឹង ប្រធាន នៅ ម៉ោតែអារងក្រោមៗទេ ហើយនឹងកងធំហ្នឹងចុះម៉ោតាមសមរភូមិ ទាល់តែដាច់ ថ្មពួកអីហ្នឹងបានគេចុះម៉ោ ។

ដានី :	ដាច់ហើយបានគេចុះ?

រតនា :	បាទ!អ្នកធំគេខ្លាចស្លាប់ដែរ ។

ដានី :	ចុះក្បាលអ្នកតាអី គេលួចកាត់តាំងពីអន្កាល់ទៅ ?

រតនា :	អាក្បាលដែលយកពីថ្មល់ដែកម៉ោហ្នឹង លោក ដែង គេទុកនៅបឹងត្រកួនហ្នឹង ដល់បាត់ អាក្បាលហ្នឹង ក៏បាត់លោក ដែងដែរហ្នឹងមិនដឹងទៅណា ។

ដានី :	ច្រើនដែរអញ្ចឹង?

រតនា :	ច្រើន វីច្រើនកាលសម័យ៩៨ ដើម៩៨រហូតដល់៩៥ វីច្រើន ។

ដានី :	ពីណាអ្នកគ្រប់គ្រង ជំនាន់ហ្នឹង?

រតនា :	គ្រាន់តែវីនេះ អ្នកដែលឈរជើងនៅនេះមានតែពួកលោក ហួត ពួកស្នា ពួកប៊ីរ៉ា ហើយមេបញ្ជាមកពីលើនោះមិនដឹងពីណាទេ ។

ដានី :	នៅខាងប៉ាវ៉ាប្ញនៅខាងអី?

រតនា :	ខាងប៉ាវ៉ា ធ្វើច្រើនដូចលក់នំអញ្ចឹង យប់ឡើង អាមេធំៗគេមិនសូវចុះម៉ោនេះទេ មានតែអាកងទ័ព នេះអាយកទៅចុងក្រោយមួយឡាន ។

ដានី :	គេដឹកឡានយកទៅម៉ង?

រតនា :	ដើរយកដឹកឡានទាំងអស់ ។

ដានី :	ចូលម៉ោដឹក?

រតនា :	ចូលម៉ោដឹក ម៉ាប្រាសាទចូលជិត១៥ក្បាលនោះ អាខ្លះប៉ុនៗខ្ញុំ អាខ្លះប៉ុនៗនោះកូន ក្មេង ហ៊ីធំៗណាស់ ដូចខ្ញុំៗជឿដែលអស់ព្រះអង្គធំនៅនេះខ្ញុំជឿ កាលនោះខាស់អស់ ទឹកជុំវិញប្រាសាទ ហើយរាំងម៉ាឆ្នាំ ។ មុននឹងវីប៉ះព្រះអង្គធំនោះខ្ញុំក៏បានចូលរួមគេ ដល់វីៗច្រើនមុននឹងប៉ះព្រះអង្គធំនោះ ភ្លៀងៗដល់ហើយ៣យប់៣ថ្ងៃ ដល់ប៉ះព្រះ អង្គធំនោះប៉ាប់មិនទាន់រាំងទេ លើកអត់រួចទេ ២០-៣០នាក់ រូបនេះគេយកកៅឡាក់ មួយ ស្ទួចដាក់ឡាន ព្រះអង្គធំហើយជើងធូរជើងអី អាទានយើងពីសម័យដើមនោះ

នាំគ្នាយកម្នាក់មួយដុំៗដាក់ហោប៉ៅ ដល់យកព្រះអង្គចេញទៅបាត់ ចាប់ផ្ដើមរាំង បណ្ដោយ រាំងរាប់ណារាប់ណីអស់ ហើយទិសហ្នឹងជុំវិញខាសអស់រលីង ។

ដានី : ចុះព្រះអង្គហ្នឹងគេយកទៅបាត់ទៅឥឡូវ?

រតនា : ហើយប្រាសាទនេះតែមិនដឹងយ៉ាំងម៉េច តែរើដឹងតែរាំងហើយ គេរើជួសជុលនេះដែល រាំងប៉ុន្មានឆ្នាំនេះ ខ្ញុំថាម៉ោពីសែនអត់ត្រូវ បានខ្ញុំជឿជាក់ហ្នឹង ព្រោះខ្ញុំធ្លាប់ដឹងប្រវត្តិពូ តៗគ្នាគេនិយាយដែលរឿងប្រាសាទនេះ ដែលសម្ដេចគាត់ក៏សាង ជ័យវរ្ម័នគាត់ កសាងដើម្បីតំកល់ឲ្យកូន ថាបើមានអ្នកណាគេម៉ោ អីពាក្យគេនិយាយម៉េចនោះខ្ញុំភ្លេច អាត្រង់នោះ ហានថាម៉ោនៅប្ញម៉ោគ្រប់គ្រងឲ្យប្រាសាទនេះស្រុត ហើយខ្វាចគេដាក់ ណាទៀតទេ អារឿងបណ្ដាសាស៍ពីដើមខ្ញុំមិនសូវដឹងដែរ ចេះតែជឿទៅ ។

ដានី : បាទ!អញ្ចឹងកាលជំនាន់៩០ជាងហ្នឹងពូនៅប៉ៃរ៉ាទេ ?

រតនា : បាទ!ប៉ៃរ៉ា ។

ដានី : ចុះពូម៉េចដែរដល់ពេលឆ្នាំហ្នឹង?

រតនា : គេហៅទៅហ្នឹង ខ្ញុំថាឈប់ទៅហើយ ប៉ៃរ៉ាខ្ញុំឈប់ធ្វើហើយ អត់បានរបប របបខ្ញុំរាប់ ម៉ឺន តែមួយបាតខ្ញុំមិនបានចាយផង ។

ដានី : អត់បានទេ?

រតនា : អត់!លោកគ្រូអើយ តែមួយបាតមិនបានផង បានអីកាំភ្លើងខ្ញី កាំភ្លើងអី គ្រាប់រំសេវ ប្រគល់ឲ្យគេអស់ អត់បានទេ ឈប់ដៃទទេ គេម៉ោតាមទៀតតែខ្ញុំអត់ទៅ ខ្ញុំថាមិនទៅ ទេខ្ញុំឈប់ហើយ ណារកតែបោកគេ គ្នាអត់មានប្រាក់ខែស៊ីទេ ដល់ម៉ោវៃសុទ្ធតែដួល មានរង្វាន់ អាណាវៃដាច់អត់ ។

ដានី : ពេលវៃប្រាប់ថាដួល ហើយឲ្យមានរង្វាន់ ដល់ពេលវៃឈ្នះអត់ឲ្យ?

រតនា : បាទ!អត់ឲ្យមិនដែលបានទេ ដល់អញ្ចឹងលែងមានកម្លាំងចង់ទៅធ្វើទៀតដែរ ។

ដានី : ចុះកាលពីលក់ក្បាលអ្នកតាគេមានយកលុយមកចែកកងទ័ពអីដែរប្ញអត់?

រតនា : អត់ទេ!ដាក់ហោប៉ៅរៀងខ្លួនហើយ ។

ដានី : មេៗហ្នឹង?

រតនា : បាទ!មេៗហ្នឹង បើប្រពន្ធខ្ញុំចូលគេបានប៉ុន្មានយប់ គេឲ្យបាន៩៥០ដែរ ។

ដានី : ៩៥០បាត?

រតនា : បាទ!៩៥០បាត ។

ដានី ៖ អញ្ចឹងប្រជាជនគេឲ្យទៅជួយដែរ?

រតនា ៖ កាលនោះ មនុស្សដូចវាមិនទាន់ឈប់រើ គេហៅក៏ទៅគេ ស្មានតែបានប្រាក់ច្រើន ។

ដានី ៖ ដល់ហើយគេឲ្យប៉ុណ្ណឹង?

រតនា ៖ បាទ!បានប៉ុណ្ណឹងឯងខ្ញុំឈប់ទៅ អ្ហ៎!មិនបំរើគេទេ ។

ដានី ៖ ចុះមេធំពីណាគេកាលហ្នឹង?

រតនា ៖ ភោគ ឈាហ្នឹងហើយមេ បន្ទាប់មកតា ហេង ដែលមេយើងកាន់កាប់តំបន់ ស្តី ហេង ទេ សព្វថ្ងៃគាត់កងពលតូចលេខប៉ុន្មានទេនៅយើងនេះ ឈា ឈប់ហើយទៅខាងណា ខាងណីអស់ហើយ ។

ដានី ៖ ពូធ្លាប់បានទៅស៊ីឈ្នួលរើនឹងគេដែរ?

រតនា ៖ រើ ខ្ញុំធ្វើនៅស្រុក ។

ដានី ៖ គេឲ្យលុយប៉ុន្មាន?

រតនា ៖ គេជួល គេឲ្យមា៉ប្រាសាទហ្នឹងគេឲ្យ១ម៉ឺនបាត ។

ដានី ៖ ឲ្យរើទាំងអស់?

រតនា ៖ ឲ្យរើទាំងអស់ ឲ្យរើឲ្យដល់បាតវា គ្នា១២នាក់ គាស់ទម្លាក់ៗទៅ មានដឹងរឿងអីឲ្យតែបានប្រាក់ គាស់ទម្លាក់ៗអត់ អត់មានឃើញអីទេ រលីងឈើញអត់មានឃើញអីទេ ។ អាពួកខាងសម្តេចគេរើខាងកណ្តាល ប្រាសាទកណ្តាលដល់រើប៉ះអាធំ ។

ដានី ៖ ប៉ះអីគេហ្នឹង?

រតនា ៖ រូបសំណាក់ព្រះ នាក់តាហ្នឹងហើយ ។

ដានី ៖ រើឃើញគេយកហើយ?

រតនា ៖ បាទ!តែឲ្យគេរើគេឃើញគេយកហើយ មុខ៣ ក្បាលវាប៉ុនពាង ហើយខ្លួនពេញមា៉ប្រាសាទៗហ្នឹងធំណាស់ប្រាសាទហ្នឹង អន្លុយពេនពេញសល់តែផ្លូវប៉ុននេះសងខាងៗ ។

ដានី ៖ ចំកណ្តាលប្រាសាទ?

រតនា ៖ បាទ!

ដានី ៖ លោក ដែង គាត់ទៅណាទៅ?

រតនា ៖ គាត់ទៅអាមេរិចដឹង ។

ដានី ៖ គាត់ធ្វើអីលោក ដែងហ្នឹង?

រតនា ៖ ប្រធានភូមិភាគ?

ដានី ៖ ឈ្មោះអី ឈ្មោះអីដែន?

រតនា ៖ ឈ្មោះ ដែន តែមិនដឹងអីដែន ។

ដានី ៖ ពូឈប់ធ្វើទ័ពតាំងពីឆ្នាំណា?

រតនា ៖ ឈប់ពីសម័យ៩៣ ។

ដានី ៖ ៩៣បោះឆ្នោតហ្នឹង?

រតនា ៖ បាទ!

ដានី ៖ ឈប់ទៅមកធ្វើប្រជាជនវិញ?

រតនា ៖ បាទ!មកធ្វើស្រែវិញ ។

ដានី ៖ ចុះប្រាសាទអូហ្នឹងគេនៅតែគាស់យកមកលក់ទៀតឬនៅ?

រតនា ៖ ឈប់យូរហើយ សព្វថ្ងៃគេមានអ្នកការពារ គេក៏សាង ។

ដានី ៖ ឥឡូវនៅសល់ទេរូបសំណាក់ហ្នឹង ឬក៏ជិតអស់ហើយ?

រតនា ៖ មិនដឹង ព្រោះវាបាក់គ្រប់កន្លែង ដែលរើចេញវាបាក់ ។

ដានី ៖ អញ្ចឹងពូខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំពីទៀតហើយ ពូមានអីបន្ថែម ត្រូវសួរខ្ញុំវិញនូវអារអ៊ី ដែលខ្ញុំអត់បានសួរនាំពូ?

រតនា ៖ អត់មានអីបន្ថែមទៀតទេ ។

ដានី ៖ ចុះពូសព្វថ្ងៃពូដែលឮពត៌មានទាក់ទង ពីសាលាក្ដីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ពូដែលឮទេ?

រតនា ៖ ឮ បើរ៉ាត់យូស្ដាប់ ។

ដានី ៖ ចុះការកាត់ក្ដីកន្លងម៉ោនេះ ដូចថាសវនាការដែលគេជំនុំជំរះរឿងក្ដីរបស់ឌុចនេះ ពូមានដែលតាមដានទេ?

រតនា ៖ តាមដានដែរ ។

ដានី ៖ ពូមានដឹងស្គាល់ឌុចដែរ?

រតនា ៖ មិនស្គាល់ទេ!ឮតែឈ្មោះ ។

ដានី ៖ ឮតែឈ្មោះគាត់ធ្វើអី?

រតនា ៖ ថាប្រធានគុកទួលស្លែង ។

ដានី ៖ បាទ!ចុះឥឡូវគេកាត់ទោសគាត់ ហើយពូមានដឹងថាគាត់គេកាត់ទោសដាក់គុកប៉ុន្មានឆ្នាំដែរ?

រតនា ៖ ប៉ុន្មានដែរខ្ញុំភ្លេចបាត់ហើយ ខ្ញុំស្តាប់លើកមុនឮតែ១៥ឆ្នាំទេ ហើយគេមានបន្ថែមទៀតទេ?

ដានី ៖ បាទ!និយាយរួមគេកាត់ទោសគាត់ឲ្យជាប់គុក៣៥ឆ្នាំ ។

រតនា ៖ បាទ!

ដានី ៖ ៣៥ឆ្នាំ ដោយសារគាត់ កាលគេចាប់គាត់កាលពីឆ្នាំ៩៨-៩៩ហ្នឹង ទៅឃុំនៅតុលាការយោធាហ្នឹងវាខុសពីនីតិវិធីខាងច្បាប់ អញ្ចឹងគេសម្រាល៥ឆ្នាំ នៅសល់៣០ឆ្នាំ ។

រតនា ៖ បាទ!

ដានី ៖ ដល់ពេលតាំងពីរយៈពេលដែលគេឃុំគាត់ពីឆ្នាំ៩៩ដល់ឆ្នាំ២០១០ហ្នឹង វា១១ឆ្នាំៗ ហើយពេលដែល បើកសវនាការហ្នឹង គាត់សហការជាមួយខាងសាលាក្តីហ្នឹងឆ្លើយអីសហការជាមួយគេអញ្ចឹង គេគិតរយៈពេលពីឃុំខ្លួនពី៩៩ដល់២០១០ហ្នឹង១១ឆ្នាំ ទៀតអញ្ចឹង១១ឆ្នាំដកនឹង៣០ឆ្នាំ វានៅសល់តែ១៩ឆ្នាំ អញ្ចឹងបន្ទាប់ពីហ្នឹងទៅ ឌុចត្រូវនៅជាប់ពន្ធធាគារតែ១៩ឆ្នាំ អញ្ចឹងពូគិតថាសមរម្យដែរឬអត់?

រតនា ៖ ទេ!បើដូចខ្ញុំ ខ្ញុំថាមិនត្រូវទេលោកគ្រូ បើគាត់សម្លាប់គេអស់ឡើងរាប់រយ ដល់ច្បាប់ឲ្យថាដាក់គុកគាត់អញ្ចឹង បើច្បាប់ថាគាត់ងាប់ច្រើនចឹង ដូចគេថាឈាមសងដោយឈាមសម្លាប់គាត់វិញទៅបានល្អ គាត់ងាប់តែឯង បើគេៗងាប់រាប់ពាន់រាបម៉ឺន ខ្ញុំឆ្ងល់ត្រង់នេះមួយ ឆ្ងល់តែគេសម្អាសន៍ដូចជា ឌុច អៀង សារី ខៀវ សំផន ដល់សួរទៅ ខៀវសំផន ឆ្លើយថាខ្ញុំមិនបានបញ្ជាឲ្យសម្លាប់ទេ បាទ!ខ្ញុំឆ្ងល់ដែលថាដែលខ្ញុំធ្វើទ័ព ធ្វើខ្មែរក្រហមខ្ញុំធ្វើទ័ពមែន ប៉ុនតែច្បាប់មាត៌ាដែលខ្ញុំរៀន៣ឆ្នាំប៉ុន្មានខែហ្នឹង ខ្ញុំរៀនអាច្បាប់កម្មុយនីសគេលោកគ្រូ!

ដានី ៖ បាទ!

រតនា ៖ គេថា រណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងគឺថាខ្លាំងណាស់ ច្បាប់ហ្នឹងគឺថា ខ្ញុំរៀនអាឯកសារហ្នឹង ខ្ញុំធ្វើប៉ារ៉ាខ្ញុំរៀននៅស្រុកថៃ គេយកអាឯកសារហ្នឹងម៉ោទៀត ប៉ុនសុទ្ធតែភាសាអង់គ្លេស គេដាក់រូបសីហនុ ខៀវ សំផន អៀង សារី មានតែបីនាក់ហ្នឹង ។

ជិតខាង ៖ ប៉ុល ពតនោះ?

រតនា ៖ ប៉ុល ពត អត់មានទេ ប៉ុល ពត ទើបម៉ោក្រោយទេ ពត គេគុបតែងឲ្យឡើងតំណែងក្រោយនេះទេ ដែលយើងនេះថាមិនមានសីហនុទេធ្វើខ្មែរក្រហមនោះ ប៉ុនក្នុងឯកសារ

គេដាក់សីហនុប្រធាន បើកន្លែងគេដាក់បង់កបេះ ហើយស្បែកជើងបូព៌ាហ្នឹង អាស្បែកជើងនេះហ្នឹង ។

ដានី : បាទ!ស្បែកជើងកង់ឡាន?

រតនា : បាទៗ!ស្បែកកង់ឡានហ្នឹងឈរ សីហនុម៉ោ ខៀវ សំផន អៀង សារី ដាក់ក្របសៀវភៅហ្នឹង ភាសាអង់គ្លេស សៀវភៅខ្ញុំរៀន ដល់រៀនគ្រូថានេះ សម័យប៉ុល ពតនេះអាបីនាក់ហ្នឹងដឹកនាំ ដល់បន្ទាប់ម៉ោ នេះខ្ញុំនិយាយតែកាលខ្ញុំទៅរៀនទេ ។

ដានី : បាទ!

រតនា : ប៉ុន សីហនុ ធ្វើខែលថាចូល អាគេថាចូលព្រៃភាគីអីនោះ ដែលឯកសារហ្នឹងគេចងក្រងនៅប្រទេសអង់គ្លេស សុទ្ធតែភាសាអង់គ្លេសតែថៃគេមកបង្រៀន ដែលខ្ញុំទៅរៀននៅប្រទេសថៃ៣ខែ អាខ្លះទៅម៉ាលេ អាខ្លះនៅប្រទេសថៃ នៅឆាក់បរី ដុកបរី ឆាក់បរីក៏ខ្ញុំរៀន ដុកបរីក៏ខ្ញុំរៀន ឆាយបរីក៏ខ្ញុំរៀន ដាក់ឆងក៏ខ្ញុំរៀន ប្រទេសថៃធ្វើប៉ាវ៉ាបានតែរៀនទេធ្វើមេអត់បានទៅណាទេ ដល់នេះទៅអាមាគាំហ្នឹងសំខាន់ណាស់ អត់មានសម្ងាប់ មានតែសង្គ្រោះនឹងបំរើ ហើយអត់មានសម្ងាប់ អត់មាននេះទេ ហើយមានប្រាក់ចាយ ប្រាក់មានប្រាក់បោះពុម្ពរួចហើយ ឃើញទាំងប្រាក់ទៀត ។

ដានី : ចុះពូរៀនឆ្នាំ?

រតនា : រៀន កាលប៉ុន្មានទេ ខ្ញុំនៅសាយធូហើយ នៅបាន៤-៥ខែហើយ ខ្ទង់៨៤-៨៥ហ្នឹង ហើយខ្ញុំទៅរៀននៅប្រទេសថៃ គេហៅមេៗទៅរៀននៅហ្នឹង ដល់រៀនរួចចប់អស់ ហើយអារឿងមាគាំ មានប្រាក់ចាយ អត់មានបាយរួមអត់មានអីទេ បដិវត្តន៍វានេះ បដិវត្តន៍ត្រឹមត្រូវណាស់ រីកចំរើន មាគាំវាមិនអន់ទេ ល្អណាស់មាគាំវាហ្នឹង គ្មានសម្រាប់គ្មានសម្រាប់គ្មានអីទេ ដល់អៀង សារី ខ្ញុំស្ដាប់ទៅដែលគេសម្ភាសន៍ហ្នឹង ខៀវ សំផន គេថាមាគាំខ្ញុំអត់មានឲ្យសម្ងាប់ទេ គ្រូឯងធ្លាប់ដឹងហើយគាត់អត់មានឆ្លើយថាសម្ងាប់ណា៎ គាត់អត់មានដងទេ ហើយចុះអាមាគាំហ្នឹងម៉ោពីណា អ្នកណាអ្នកអនុវត្តន៍ អ្នកណាធ្វើ បើគិតជាមេគេមិនដឹង អ្នកណាអ្នកបញ្ជា ។

ដានី : បាទ!អញ្ចឹងហើយ យើងចាំមើលដើមឆ្នាំក្រោយហ្នឹង គេនឹងបើកសវនាការជំនុំជំរះពួកគាត់មាន អៀង សារី ខៀវ សំផន នួន ជា នឹងអៀង ធិរិទ្ធប្រពន្ធរបស់អៀង សារី ចាំមើលពេលដែលបើកសវនាការនេះយើងចាំតាមដានទាំងអស់គ្នា តើគាត់ឆ្លើយយ៉ាងម៉េចហើយគេមានភស្តុតាងអីយ៉ាងម៉េច ដើម្បីចោទប្រកាន់គាត់ ហើយគាត់ឆ្លើយយ៉ាង

ម៉េចពេលហ្នឹង អញ្ចឹងពូចាំតាមដានហើយចាំឆ្លើយទាំងអស់គ្នា ឥឡូវហ្នឹងខ្ញុំក៏មិនដឹងដែរ ពីព្រោះពេលហ្នឹងសវនាការគេបើកឡើង គាត់នឹងឆ្លើយ ហើយគេចោទគាត់យ៉ាងម៉េច គាត់ឆ្លើយដោះយ៉ាងម៉េច គាត់និយាយដោះយ៉ាងម៉េចខ្លះ យើងចាំស្តាប់ទាំងអស់គ្នាពេលហ្នឹងទៀត ។

រតនា : បាទៗ!

ដានី : អញ្ចឹងពូៗគិតថាគេបង្កើតតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមហ្នឹងត្រឹមត្រូវដែរឬក៏យ៉ាងម៉េច តាមចិត្តរបស់ពូ?

រតនា : ទេ!ខ្ញុំថាត្រឹមត្រូវក៏ដូចជាមិនត្រឹមត្រូវ ព្រោះថាដូចជាវាមិនស្មើណាលោកគ្រូ ។

ដានី : មិនស្មើម៉េច?

រតនា : មិនស្មើដូចថាវាអស់ឡើងប៉ុន្មាន៨០លាន ដូចថាកាត់ទោសដូចវាស្រាលពេកហើយក្នុងចិត្តខ្ញុំទេ វាតូចចិត្តនឹងណា រឿងបងប្អូនខ្ញុំក៏ងាប់ អ្នកណាក៏ងាប់ដែរ វៃចោលមិន គិច ។

ដានី : បាទ!

រតនា : បាទ!ដូច្នេះ ខ្ញុំធ្វើដែរតែខ្ញុំមិនបានសម្លាប់អ្នកណាទេ ។

ដានី : បាទ!

រតនា : ខ្ញុំបាញ់តែលាវទេ វៃតែលាវមួយថ្ងៃៗ ធ្វើទ័ពដូចគ្នា ដូច្នេះបានថាអារឿងមាគ៌ាទ័ពដែលខ្ញុំនៅតាមជាយដែនអត់ដឹងទេ អត់ដឹងថាគេសម្លាប់បងប្អូនធ្វើកងចល័ត គេជីកប្រឡាយ ជីកទឹកទេ ។

ដានី : បាទ!

រតនា : រហូតដល់គេរំដោះ៧៥ភ្លីបម៉ោ គេយកពួកខ្ញុំនៅជាយដែននឹងហើយ គេដកមួយកងធំទៅលេងពេញ៣ថ្ងៃ ឲ្យទៅតំណាងការពារនោះ ទៅលេងពេញ៣ថ្ងៃ ដល់ម៉ាផ្អែតរួចបកមកវិញយកម៉ាកងធំទៅទៀត ទៅមានអីឃើញតែផ្ទះថ្មហ្នឹង អ្នកស្រុកគេរត់ចេញទៅណាអស់អត់ដឹងរឿង ។

ដានី : បាទ!

រតនា : បាទ!ដល់នេះមនុស្សឡើងៗពេញកន្លែងសីហនុ ខ្ញុំថាកន្លែងសីហនុ ត្រង់ណាៗ ហើយអាពួកពេញសុទ្ធតែអាវខ្មៅមើលទៅពពាក់ពពើតពេញហ្នឹង ពួកខ្ញុំចុះម៉ោ គេហៅទ័ពស្រួចមជ្ឈិមបក្សគេហ្នឹងសុទ្ធតែអាអាវខៀវងងឹតគេនោះ ។

ដានី ៖ បាទ!

រតនា ៖ ទៅត្រង់ណាគេស្មាគមន៍ត្រង់នោះ មិនដែលបានដាំបាយណា ចូលទៅគេដាំបាយឲ្យហូប ទៀតពួកខ្ញុំហ្នឹង ដូចមានរឿងខ្លាំង យួនវាថាភូមិភាគពិសេសនោះ ។

ដានី ៖ បាទ!

រតនា ៖ បាទ!អាពិសេសនេះអត់បានទេខ្លាំងវាខ្លាំង ទ័ពតាហាន់ខ្លាំងណាស់ វ៉ៃមេចោលបាត់វា ខ្លាំងពេក ហើយដែលបញ្ហាការដែលតាហាន់គាត់អប់រំកូនចៅម៉េចៗនោះថា បដិវត្តន៍រណសិរ្សរួបរួមជាតិកម្ពុជាប្រជាធិបតេយ្យ ធិបតេយ្យគឺថាវាស្មើភាពហើយ ។

ដានី ៖ បាទ!

រតនា ៖ បាទ!គាត់ថាមានឡានជិះទាំងអស់គ្នា ។

ដានី ៖ បាទ!

រតនា ៖ មានម៉ូតូៗគ្រប់ផ្ទះ ឡានៗទាំងអស់គ្នា មានបាយស៊ីៗគ្រប់គ្នា អត់មានអ្នកណាក្រអ្នកណាមានទេ ប្រជាធិបតេយ្យ ។

ដានី ៖ បាទ!

រតនា ៖ បាទ!ហើយប្រាក់ក៏មានចាយ អារឿងប្រាក់ហូរ យន់ ហូរ នឹម គេសម្លាប់ចោល ។

ដានី ៖ បាទ!

រតនា ៖ អាពតឡើងកាន់តំណែង សម្លាប់ ហូរ យន់ ហូរ នឹម ចោល សម្លាប់រឿងអីរឿងប្រជុំអត់ត្រូវគ្នា ។

ដានី ៖ បាទ!

រតនា ៖ បាទ!ខ្ញុំរៀនតៗទេមិនដឹងទេ រៀនតគ្នាគឺថា ហូរ យន់ ហូរ នឹម នេះឲ្យចាយប្រាក់ដល់ហើយគេតំឡើងអាពតឲ្យធ្វើមេមកដល់អាពតគេថាចាយប្រាក់អត់បានទេ ប្រាក់តែហានចាយ ខ្លាំងនៅស៊ីរូងផ្ទៃក្នុងតាមប្រាក់នេះទៀត ដូច្នេះប្រាក់ឈប់ចាយ មាសឈប់ចាយ ប្រាក់បោះពុម្ពចោលដុតចោលខ្ទិច ពតដុតចោលអស់ វ៉ៃចោល ហូរ យួន ហូរ នឹម វ៉ៃចោលអស់ មានសីហនុ ខៀវ សំផន ហូរ យន់ ហូរ នឹម នេះមេធំៗដែលចងក្រងរណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងលទ្ធិម៉ៅសេទុងបាទនេះរឿងវា ។

ដានី ៖ បាទ!ចុះពូម៉េចដឹងរឿងហ្នឹង?

រតនា ៖ ចុះខ្ញុំរៀននោះ ។

ដានី ៖ រៀនតាមណា?

រតនា ៖ តាមលោកគ្រូលំហាត់ហ្នឹង ។

ដានី ៖ រៀនកាលពីឆ្នាំណា?

រតនា ៖ រៀនឆ្នាំ៧៣-៧៤ ។

ដានី ៖ ចុះរឿងគេសម្លាប់វ៉ៃ ហូរ យន់ ហូរ នឹម ចោលហ្នឹងអាហ្នឹងពូដឹងតាមពីណា?

រតនា ៖ អាហ្នឹងខ្ញុំដឹងតាមមេខ្ញុំ ដូចមេបញ្ជាការខ្ញុំពីលើម៉ោ វរៈសេនាធំ វរៈសេនាភូមិភាគគេប្រាប់ម៉ោ គេបង្រៀនម៉ោ ។

ដានី ៖ បាទ!

រតនា ៖ គេយកទាំងក្រដាស់ប្រាក់មកបង្ហាញខ្ញុំទៀត ក្រដាស់ប្រាក់គេបោះពុម្ពម៉ោ ។

ដានី ៖ បាទ!អញ្ចឹងខ្ញុំអរគុណពូ ។

រតនា ៖ បាទ!

**ចប់**